**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០៦៩/១៥ ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ សន/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## <u>សម្រេច</u>

**ប្រការ ១**.- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទទួលបន្ទុកការងារតាក់តែងគោលនយោបាយអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនិងគ្រប់គ្រងលើការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងតាមច្បាប់ស្តីពីការងារ ប្រមូលចងក្រង និងគ្រប់គ្រងព័ត៌មានទីផ្សារការងារក្នុង និងក្រៅប្រទេស ធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងអភិវឌ្ឍស្តង់ដានិងកម្មវិធីសិក្សា។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ ២**.- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដឹកនាំដោយអគ្គនាយកមួយរូប និង មានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

**ប្រការ ៣**.- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមាននាយកដ្ឋានចំនួន ៦ និង លេខាធិការដ្ឋាន ១ រួមមាន៖

១-នាយកដ្ឋានព័ត៌មានទីផ្សារការងារ

២-នាយកដ្ឋានបណ្តុះបណ្តាល

៣-នាយកដ្ឋានស្តង់ដានិងកម្មវិធីសិក្សា

៤-នាយកដ្ឋានធានាគុណភាព

៥-នាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ

៦-នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា

៧-លេខាធិការដ្ឋាន

**ប្រការ ៤**.- នាយកដ្ឋានចំណុះឲ្យអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅដាច់ដោយឡែក។

**ប្រការ ៥**.- លេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលមានរចនា សម្ព័ន្ធស្មើនឹងការិយាល័យនៅថ្នាក់កណ្តាល ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយ ចំនួនជាជំនួយការ។ លេខាធិការដ្ឋានមានភារកិច្ចដូចតទៅ៖

- សម្របសម្រួលរាល់ឯកសារលិខិតចេញ-ចូល របស់អគ្គនាយកដ្ឋាន
- សម្របសម្រួលរាល់កិច្ចការរបស់អគ្គនាយកដ្ឋាន ជាមួយទីស្តីការក្រសួង នាយកដ្ឋាននានាក្រោម ឱវាទក្រសួង មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ក្រសួង-ស្ថាប័នរបស់រាជ រដ្ឋាភិបាល អង្គការជាតិ-អន្តរជាតិ និង ដៃគូអភិវឌ្ឍន៍នានា
- គ្រប់គ្រង និងចាត់ចែងរាល់ឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គនាយកដ្ឋាន
- រៀបចំទុកដាក់ ថែរក្សា និងគ្រប់គ្រងរាល់ឯកសារ លិខិតរបស់អគ្គនាយកដ្ឋាន
- ថែរក្សា គ្រប់គ្រងសម្ភារ បរិក្ខារ ចលនទ្រព្យ និងអចលនទ្រព្យនានារបស់អគ្គនាយកដ្ឋាន
- ណែនាំរបៀបរបបការងាររដ្ឋបាលរបស់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋាន
- រៀបចំអង្គប្រជុំ និងធ្វើរបាយការណ៍ ឬកំណត់ហេតុអង្គប្រជុំរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗតាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន

**ប្រការ ៦**.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។ ៕

**ប្រការ ៧.-** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

អ៊ិត សំហេង

<u>ចម្លងជូន៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ:** ០៦៦/១៥ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥

